State of California-Health and Human Services Agency
**Department of Health Care Services**
P.O. Box 989009, West Sacramento, CA 95798-9009

?-

XX/XX/XXXX

Mr. John Sample
1234 Sample Street
Anytown, CA 90000

# ដំណឹងសំខាន់ស្តីពីការធានារ៉ាប់រងសុខភាពរបស់អ្នក

ជូនចំពោះ John Sample

ដំណឹងល្អ! ច្បាប់ថ្មីមួយរបស់រដ្ឋ California គឺច្បាប់ព្រឹទ្ធសភា (Senate Bill) (SB) 75 មានន័យថា អ្នកទទួលបានអត្ថប្រយោជន៍ Medi-Cal បន្ថែម។ ក្មេងខ្លះ ដែលមានអាយុក្រោម 19 ឆ្នាំ ប្រហែលអាចទទួលអត្ថប្រយោជន៍វិសាលភាពពេញលេញបាន។ ប្រសិនបើអ្នកមានសិទ្ធិចូលរួម អត្ថប្រយោជន៍ Medi-Cal វិសាលភាពកំណត់របស់អ្នក នឹងផ្លាស់ប្តូរទៅជាអត្ថប្រយោជន៍វិសាលភាពពេញលេញ។

### តើច្បាប់ថ្មីគឺជាអ្វី?

SB 75 គឺជាច្បាប់ថ្មីមួយ នៅក្នុងរដ្ឋ California។ វាផ្តល់ Medi-Cal វិសាលភាពពេញលេញ ដល់ក្មេងៗមានអាយុក្រោម 19 ឆ្នាំ។ ហើយស្ថានភាពអន្តោប្រវេសន៍របស់អ្នកមិនបានគិតដែរ។ អ្នកនៅតែត្រូវបំពេញលក្ខខណ្ឌ Medi-Cal ដទៃៗទៀត ដើម្បីមានសិទ្ធិចូលរួម។ SB 75 នឹងចាប់ផ្តើមនៅ ឬក្រោយពីថ្ងៃទី 1 ខែឧសភា ឆ្នាំ 2016។

### តើ Medi-Cal វិសាលភាពពេញលេញ គឺជាអ្វី?

Medi-Cal ផ្តល់ការថែទាំសុខភាព ដោយមិនគិតថ្លៃ ឬដោយថ្លៃថោក សម្រាប់អ្នកមួយចំនួនដែលរស់នៅក្នុងរដ្ឋ California។ Medi-Cal វិសាលភាពពេញលេញ ធានារ៉ាប់រងច្រើនជាងការថែទាំ នៅពេលដែលអ្នកមានភាពអាសន្ន។ វាផ្តល់ការថែទាំសុខភាព ការថែទាំធ្មេញ ការថែទាំសុខភាពផ្លូវចិត្ត និងការថែទាំភ្នែក។ វាថែមទាំងធានារ៉ាប់រងចំពោះការព្យាបាលការប្រើប្រាស់សុរា និងថ្នាំញៀន និងថ្នាំសង្កូវដែលគ្រូពេទ្យរបស់អ្នកបញ្ជា និងជាច្រើនទៀត។ អ្នកអាចស្វែងយល់បន្ថែមអំពី Medi-Cal នៅ **www.dhcs.ca.gov**។

### តើធ្វើដូចម្តេចឲ្យដឹងថា តើខ្ញុំអាចទទួលបាន Medi-Cal វិសាលភាពពេញលេញ?

អ្នកនឹងទទួលសេចក្តីជូនដំណឹងមួយ តាមប្រៃសណីយ៍។ វានឹងប្រាប់អ្នកថា តើអ្នកអាចទទួលអត្ថប្រយោជន៍ Medi-Cal វិសាលភាពពេញលេញ បានឬមិនបាន។

### តើខ្ញុំត្រូវធ្វើអ្វីឥឡូវនេះ?

ឥឡូវនេះ មិនមានការផ្លាស់ប្តូរចំពោះអត្ថប្រយោជន៍ Medi-Cal របស់អ្នកទេ។ ដូច្នេះ កុំអាលធ្វើអ្វី។ ដោយសារអ្នកមាន Medi-Cal ស្រាប់ហើយ អ្នកមិនបាច់បំពេញពាក្យសុំ Medi-Cal ថ្មីនោះទេ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកទទួលកញ្ចប់សុំបន្តអត្ថប្រយោជន៍ជាថ្មីតាមប្រៃសណីយ៍ អ្នកគួរតែបំពេញវា។ ពេលនោះទើបអ្នកអាចនៅតែទទួលអត្ថប្រយោជន៍វិសាលភាពកំណត់របស់អ្នកបាន មុននឹងច្បាប់ថ្មីចាប់ផ្តើមអនុវត្ត។ នៅ ឬក្រោយពីថ្ងៃទី 1ខែឧសភា ឆ្នាំ 2016 អ្នកនឹងអាចផ្លាស់ប្តូរទៅអត្ថប្រយោជន៍វិសាលភាពពេញលេញ។ ខោនធីប្រហែលនឹងស្នើសុំព័ត៌មានអំពីការបន្តអត្ថប្រយោជន៍ជាថ្មីរបស់អ្នក។ នៅពេលណាដែលមានការផ្លាស់ប្តូរ ក្នុងព័ត៌មានរបស់អ្នក សូមឲ្យប្រាកដថា ប្រាប់ដល់ការិយាល័យប្រចាំខោនធីរបស់អ្នក។

ដោយសារអ្នកកំពុងទទួលសេវា Medi-Cal ឥឡូវនេះ អ្នកគួរតែមានប័ណ្ណ Medi-Cal ID មួយសន្លឹក។ ប័ណ្ណនេះ ហៅថាប័ណ្ណសំគាល់អត្ថប្រយោជន៍ (Benefits Identification Card ) (BIC)។ BIC គឺជាកាតផ្លាស្ទិកពណ៌សមួយ ជាមួយអក្សរពណ៌ខៀវ។ គ្រូពេទ្យ ឬគ្លីនិក ត្រូវការមើល BIC របស់អ្នក នៅពេលអ្នកទៅទទួលការថែទាំ។ ដូច្នេះ សូមយក BIC របស់អ្នក នៅពេលទៅជួបគ្រូពេទ្យរបស់អ្នកជានិច្ច។ ប្រសិនបើអ្នកមិនមាន BIC របស់អ្នក សូមទូរស័ព្ទទៅការិយាល័យប្រចាំខោនធីរបស់អ្នក ដើម្បីស្នើសុំប័ណ្ណថ្មី។

## តើខ្ញុំនឹងប្រើប្រាស់ Medi-Cal វិសាលភាពពេញលេញថ្មីរបស់ខ្ញុំ យ៉ាងដូចម្ដេច?

អ្នកនឹងត្រូវចុះឈ្មោះនៅក្នុងគម្រោងសុខភាព Medi-Cal គ្រប់គ្រងការថែទាំ (គម្រោង Medi-Cal ) មួយ។ លុះត្រាអ្នកចុះឈ្មោះនៅក្នុងគម្រោង Medi-Cal មួយ អ្នកនឹងទទួលអត្ថប្រយោជន៍វិសាលភាពពេញលេញរបស់អ្នក តាមរយៈ Medi-Cal កម្រៃសម្រាប់សេវាសិន។ ជួនកាល នេះត្រូវបានគេហៅថា Medi-Cal ធម្មតា។ នៅក្នុង Medi-Cal ធម្មតា អ្នកអាចជួបគ្រូពេទ្យណាក៏បាន គ្រូពេទ្យធ្មេញណាក៏បាន ឬឱសថស្ថានណាក៏បាន ឲ្យតែយក Medi-Cal។

នៅក្នុងគម្រោង Medi-Cal អ្នកត្រូវតែជួបគ្រូពេទ្យដែលធ្វើការជាមួយនឹងគម្រោងនោះ។ អ្នកនឹងនៅតែទទួលការថែទាំ បើអ្នកមានភាពអាសន្ន ឬបើអ្នកមានផ្ទៃពោះ។ ប៉ុន្តែ នៅក្នុងគម្រោង Medi-Cal អ្នកថែមទាំងអាចជួបពេទ្យឯកទេស ទទួលការថែទាំសម្រាប់ស្ថានភាពជំងឺមួយ ឬទទួលការវះកាត់។ គម្រោង Medi-Cal នឹងធានារ៉ាប់រងចំពោះសេវាទាំងនេះ ប្រសិនបើវាមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ។ អ្នកនឹងទទួលកញ្ចប់មួយ ពីគម្រោង Medi-Cal ជម្រាបលោកអ្នកអំពីអត្ថប្រយោជន៍ទាំងអស់។

## តើគម្រោងសុខភាព Medi-Cal គឺជាអ្វី?

គម្រោង Medi-Cal គឺជាគម្រោងធានារ៉ាប់រងសុខភាពមួយ ដែលធានារ៉ាប់រងចំពោះសេវា Medi-Cal ទាំងឡាយ។ គម្រោងធ្វើការជាមួយនឹងអ្នកផ្ដល់សេវា ដើម្បីឲ្យប្រាកដថា អ្នកទទួលបានសេវាដែលអ្នកត្រូវការ ដើម្បីរក្សាសុខភាពល្អ។ គម្រោង Medi-Cal ធ្វើការជាមួយនឹងគ្រូពេទ្យរបស់អ្នក ដើម្បីគ្រប់គ្រងការថែទាំរបស់អ្នក។ នៅពេលដែលអ្នកចូលរួមក្នុងគម្រោង Medi-Cal មួយ សេវាថែទាំសុខភាពភាគច្រើនរបស់អ្នក នឹងត្រូវបានផ្ដល់ដោយគម្រោង។

## តើខ្ញុំជ្រើសរើសគម្រោង Medi-Cal យ៉ាងដូចម្ដេច?

ជម្រើសគម្រោង Medi-Cal របស់អ្នក នឹងអាស្រ័យលើខោនធីដែលអ្នករស់នៅ។ ក្រោយពីអ្នកបានផ្លាស់ប្ដូរទៅ Medi-Cal វិសាលភាពពេញលេញ អ្នកនឹងទទួលសេចក្ដីជូនដំណឹងមួយ តាមប្រៃសណីយ៍។ នេះនឹងកើតឡើងក្នុងរយៈពេលប្រហែល 2 ខែ។ សេចក្ដីជូនដំណឹងនឹងជម្រាបអ្នកអំពីជម្រើសទាំងឡាយរបស់អ្នក។ វានឹងជម្រាបអ្នកអំពីរបៀបចុះឈ្មោះ នៅក្នុងគម្រោង Medi-Cal មួយ។ សួរគ្រូពេទ្យរបស់អ្នកថា តើគាត់ធ្វើការជាមួយនឹងគម្រោង Medi-Cal មួយ នៅក្នុងខោនធីរបស់អ្នក ឬទេ។ បន្ទាប់មក អ្នកអាចជ្រើសរើសគម្រោង Medi-Cal មួយនោះបាន។

## តើខ្ញុំទទួលការថែទាំយ៉ាងដូចម្ដេច មុនខ្ញុំចុះឈ្មោះក្នុងគម្រោងសុខភាព Medi-Cal មួយ?

នៅក្នុងខែដែលអ្នកទទួល Medi-Cal វិសាលភាពពេញលេញ អ្នកនឹងទទួល Medi-Cal ធម្មតា រហូតដល់អ្នកចុះឈ្មោះក្នុងគម្រោង Medi-Cal មួយ។ អ្នកអាចជួបពេទ្យណាដែលទទួល Medi-Cal ធម្មតា។ ដើម្បីរកគ្រូពេទ្យម្នាក់ អ្នកអាចមើលតាម Google សួរមិត្តភក្តិ ឬសួរគ្រូពេទ្យ ដែលអ្នកធ្លាប់ជួបពេលកន្លងមក។ ពេលអ្នកទូរស័ព្ទទៅការិយាល័យរបស់គ្រូពេទ្យមួយ សួរថា តើពួកគេកំពុងយកអ្នកជំងឺ “Medi-Cal កម្រៃសម្រាប់សេវា” ថ្មី ឬទេ។ អ្នកក៏អាចប្រើបញ្ជីរាយគ្រូពេទ្យដែលចូលរួមក្នុងកម្មវិធី Medi-Cal កម្រៃសម្រាប់សេវាមួយនេះ ដែលមានជូនតាមអ៊ីនធឺណិត៖
**https://chhs.data.ca.gov/Facilities-and-Services/Profile-of-Enrolled-Medi-Cal-Fee-for-Service-FFS-P/nnz9-spdi**។

## តើអ្នកណានឹងធ្វើជាគ្រូពេទ្យរបស់ខ្ញុំ នៅពេលខ្ញុំនៅក្នុងគម្រោងសុខភាព Medi-Cal មួយហើយ?

អ្នកត្រូវជ្រើសរើសគ្រូពេទ្យម្នាក់ ដែលធ្វើការជាមួយនឹងគម្រោង Medi-Cal របស់អ្នក។ សួរគ្រូពេទ្យរបស់អ្នកថា តើគាត់ធ្វើការជាមួយនឹងគម្រោង Medi-Cal មួយ ឬទេ។ ប្រសិនបើគ្រូពេទ្យរបស់អ្នកធ្វើការជាមួយនឹងគម្រោង Medi-Cal មួយ នៅក្នុងខោនធីរបស់អ្នក អ្នកអាចរក្សាទុកគ្រូពេទ្យម្នាក់នោះបាន។ បន្ទាប់មក ជ្រើសរើសគ្រូពេទ្យម្នាក់នោះ នៅពេលអ្នកចុះឈ្មោះនៅក្នុងគម្រោង។

ប្រសិនបើអ្នកត្រូវការជំនួយ គម្រោង Medi-Cal នឹងផ្ញើបញ្ជីគ្រូពេទ្យមួយច្បាប់ទៅអ្នក។ ផ្នែកសេវាសមាជិករបស់គម្រោងនោះក៏អាចជួយបានដែរ។ ប្រសិនបើអ្នកមិនជ្រើសរើសគ្រូពេទ្យម្នាក់ទេ គម្រោងនឹងជ្រើសរើសម្នាក់ជំនួសឲ្យអ្នក។ អ្នកអាចផ្លាស់ប្ដូរគ្រូពេទ្យនៅពេលណាក៏បាន។ ទូរស័ព្ទទៅខ្សែទូរស័ព្ទសេវាសមាជិក របស់គម្រោង Medi-Cal របស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមមើល
**http://www.healthcareoptions.dhcs.ca.gov/HCOCSP/Enrollment/default.aspx**

**ចុះចំពោះអត្ថប្រយោជន៍ធ្មេញ យ៉ាងម៉េចដែរ?**

ជាមួយនឹង Medi-Cal វិសាលភាពពេញលេញ អ្នកនឹងទទួលសេវាថែទាំធ្មេញផងដែរ។ អ្នកអាចទទួលការពិនិត្យធ្មេញ ការថតកាំរស្មីអិក្ស ការសំអាតធ្មេញ ការប៉ះធ្មេញ និងសេវាបន្ថែមទៀត។ ប្រសិនបើអ្នករស់នៅក្នុងខោនធី Sacramento ឬ Los Angeles អ្នកនឹងទទួលកញ្ចប់មួយតាមប្រៃសណីយ៍ ដើម្បីជ្រើសរើសគម្រោងគ្រប់គ្រងការថែទាំធ្មេញ (Dental Managed Care) មួយ។ ប្រសិនបើអ្នករស់នៅក្នុងខោនធីណាផ្សេងទៀត អ្នកនឹងត្រូវបានចុះឈ្មោះនៅក្នុងកម្មវិធីកម្រៃសម្រាប់សេវា។ កម្មវិធីនេះ ហៅថា Denti-Cal។ នៅពេលដែលអ្នកមាន Medi-Cal វិសាលភាពពេញលេញហើយ យើងនឹងផ្ញើសំបុត្រមួយទៅអ្នក។ សំបុត្រនោះនឹងជម្រាបអ្នក អំពីកម្មវិធីធ្មេញ ដែលអ្នកចុះឈ្មោះក្នុងនោះ។

**ចុះបើខ្ញុំជិតឡើងអាយុគ្រប់ 19 ឆ្នាំ យ៉ាងម៉េចដែរ?**

បើអ្នកនឹងឡើងអាយុគ្រប់ 19 ឆ្នាំនៅក្នុងរយៈពេលប្រាំមួយខែខាងមុខ អ្នកអាចទទួល Medi-Cal វិសាលភាពពេញលេញ ហើយអ្នកប្រហែលអាចមានជម្រើសកាន់តែច្រើន។ អ្នកប្រហែលអាចជ្រើសរើសថា តើចុះឈ្មោះក្នុងគម្រោង Medi-Cal មួយ ឬក៏អត់។ នេះនឹងអាស្រ័យទៅតាមខោនធីដែលអ្នករស់នៅ។ អ្នកនឹងទទួលសេវានៅក្នុង Medi-Cal ធម្មតា បើអ្នកមិនចុះឈ្មោះនៅក្នុងគម្រោង Medi-Cal មួយទេ។

**តើខ្ញុំត្រូវការដឹងអ្វីទៀត?**

អ្នកខ្លះប្រហែលមិនអាចចុះឈ្មោះនៅក្នុងគម្រោង Medi-Cal បានទេ។ អ្នកមិនអាចចុះឈ្មោះនៅក្នុងគម្រោងបានទេ ប្រសិនបើ៖

- អ្នករស់នៅក្នុងខោនធីមួយ ដែលមានគម្រោង Medi-Cal ច្រើនជាងមួយ **ហើយ**
- អ្នកមានចំណែកថ្លៃ **ឬ** អ្នកមានការធានារ៉ាប់រងសុខភាពផ្សេងទៀត

អ្នកនឹងទទួលអត្ថប្រយោជន៍វិសាលភាពពេញលេញ នៅក្នុង Medi-Cal ធម្មតា។

**តើការប្រើប្រាស់ Medi-Cal វិសាលភាពពេញលេញ នឹងធ្វើឲ្យខ្ញុំក្លាយជាបន្ទុកសាធារណៈ ឬ?**

ក្រសួងសេវាថែទាំសុខភាព (Department of Health Care Services) (DHCS) រក្សាព័ត៌មានរបស់អ្នកជាសម្ងាត់។ DHCS នឹងប្រើព័ត៌មានរបស់អ្នក ដើម្បីឆែកមើលសិទ្ធិចូលរួម Medi-Cal របស់អ្នក តែប៉ុណ្ណោះ។

DHCS មិនអាចផ្តល់ដំបូន្មាន អំពីបន្ទុកសាធារណៈបានទេ។ សម្រាប់ក្រដាសព័ត៌មានស្តីពីបន្ទុកសាធារណៈ សូមមើលវិបសាយត៍របស់ សេវាសញ្ជាតិ និងអន្តោប្រវេសន៍សហរដ្ឋ (USCIS) នៅឯ៖ **http://www.uscis.gov/news/fact-sheets/public-charge-fact-sheet**។ ប្រសិនបើអ្នកមានសំនួរបន្ថែមទៀត សូមទូរស័ព្ទទៅមេធាវីអន្តោប្រវេសន៍ម្នាក់ ឬការិយាល័យជំនួយច្បាប់ក្នុងស្រុករបស់អ្នក។

មានព័ត៌មានបន្ថែមទៀត នៅក្នុងវិបសាយត៍របស់ DHCS នៅឯ៖ **http://dhcs.ca.gov/SB75**។ ចុចលើតំណភ្ជាប់ សំណួរដែលគេច្រើនសួរ (Frequently Asked Questions)។

**តើខ្ញុំអាចទូរស័ព្ទទៅអ្នកណាបាន សម្រាប់ព័ត៌មាន ឬជំនួយបន្ថែម?**

ទូរស័ព្ទទៅខ្សែទូរស័ព្ទជំនួយ DHCS Medi-Cal។ ការហៅទូរស័ព្ទនេះ ឥតគិតថ្លៃទេ។
1-800-541-5555